ពីបីទៅបួនខែ ដល់រដូវសម្រកក៏លាអ៊ុំស្រីទៅផ្ទះវិញ ទ្រាំជិះកង់ទៅរៀនទាំងត្រដាបត្រដួស ។

# វិស័យសិល្បៈ

អំណោយពីធម្មជាតិ **សុជាខ្ញុំ**មានសម្លេងពីរោះគ្រាន់បើដែរ អាចច្រៀងបំពេរចាស់ ៗ ក្នុងភូមិឲ្យត្រជាក់ចិត្តបាន ប៉ុន្តែការនេះទាល់តែមានរង្វាន់ទើបច្រៀង មិនចេះតែច្រៀងឲ្យស្ដាប់ដោយទទេ ៗ ឬច្រៀងឡេឡៃឡាដើម្បីសប្បាយឡើយ ។ **សុជាខ្ញុំ**ចេះច្រៀងតាំងពីមិនទាន់ចេះស្លៀកខោម្ល៉េះ ក្រោយមកខ្ញុំរៀនច្រៀងតាមលោក **កែវ សារ៉ាត់** អ្នកស្រុកស្ដាប់ហើយពោលសរសើរថា ដូច **កែវ សារ៉ាត់** បេះបិទ តាំងពីពេលនោះមក អ្នកស្រុកហៅ**សុជាខ្ញុំ**ថា **សារ៉ាត់ក្មេង** ហើយក្លាយជាអ្នកចម្រៀងប្រចាំសាលាតាំងពីបឋមសិក្សាមកម្ល៉េះ ។ ក្រៅពីច្រៀង ខ្ញុំអាចហួចបានគ្រប់បទ ហើយការហួចទៀតសោតខ្ញុំហួចមិនឲ្យដាច់សម្លេងទេ គឺហួចទាល់តែចប់បទមួយ ៗ ទើបឈប់ដោយប្រើទាំងខ្យល់ចេញនិងខ្យល់ចូល អ្នកស្រុកស្ដាប់ទៅ ឮហាក់ដូចជាខ្ញុំមិនដកដង្ហើមអ៊ីចឹង លើសពីនេះ ខ្ញុំអាចហួចធ្វើជាសម្លេងខ្ទុយបាន ព្រោះហេតុនោះ ចាស់ ៗ ហៅខ្ញុំថា **កុមារខ្លុយទិព្វ** ។

ផ្នែកបទភ្លេងវិញ **សុជាខ្ញុំ**មិនធ្លាប់បានរៀនពីគ្រូណាទេ ប៉ុន្តែបើខ្ញុំមានឱកាសកាន់ឧបករណ៍ភ្លេងបានប្រហែលមួយម៉ោង ខ្ញុំអាចដេញត្រូវបានមួយបទឬពីរបទភ្លាម ព្រោះខ្ញុំចេះធ្វើបទភ្លេងតាមមាត់ ហើយរាវរកសម្លេងភ្លេងតាមសូរមាត់ខ្ញុំនោះឯង ។ ផ្នែកចម្លាក់និងគំនូរ ខ្ញុំមិនជាចេះណាស់ណាទេ ប៉ុន្តែបើក្នុងចំណោមនោះ មិនមានអ្នកចេះ ខ្ញុំក៏អាចធ្វើបាន តួយ៉ាងដូចជាបទុមចេតិយដែលកំពុងកសាង **សុជាខ្ញុំ**ជាអ្នកគូរឲ្យចេញជារូបរាងដំបូង ។ ម្យ៉ាងទៀត ក្នុងនាមខ្ញុំជាកូនអ្នកស្រែ សិល្បៈធ្វើស្រែចម្ការដូចជា ភ្ជួរ រាស់ សាបព្រោះ ដកស្ទូង ច្រូតកាត់ បោកបែនជាដើម **សុជាខ្ញុំ**ចេះយ៉ាងស្ទាត់ និងធ្លាប់ប្រព្រឹត្តធ្វើយ៉ាងសកម្ម ។

# ផ្នែកសុខភាព

**សុជាខ្ញុំ** បើនិយាយពីសុខភាព ហាក់បីដូចជាចម្លែកណាស់ បើប្រៀបទៅនឹងមនុស្សធម្មតា ព្រោះអ្នកម្ដាយដំណាលប្រាប់ថា កាលខ្ញុំអាយុបាន ៦ ខែ មានរឿងអស្ចារ្យមួយកើតឡើង រឿងនោះគឺ "ថ្ងៃមួយ វេលាម៉ោង ១២ ថ្ងៃត្រង់ នៅឯរោងការដ្ឋាន ម្ដាយមីងខ្ញុំឈ្មោះ **អៀង ម៉ៅ** បានឃើញពស់ព្រៃមួយក្បាលនៅក្នុងប្រមូរកន្ទេល គាត់ក៏